
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

## 4.03 ព្រះយេស៊ូវបណ្តេញអារក្ស

ព្រះយេស៊ូវ និងពួកសិស្សរបស់ព្រះអង្គបានឆ្លងសមុទ្រមួយដោយទូកហើយជួបព្យុះដ៏ធំមួយ។ ពួកសិស្សមានការភ័យខ្លាចជាខ្លាំងតែព្រះយេស៊ូវទ្រង់បានធ្វើឲ្យខ្យល់ព្យុះស្ងប់ ដោយគ្រាន់តែកំហែងខ្យល់ និងរលកឲ្យឈប់។ នៅពេលដែលពួកគេបានទៅដល់ត្រើយម្ខាង នោះព្រះយេស៊ូវបានដឹងថា ទ្រង់នឹងប្រោសបុរសម្នាក់ដែលត្រូវការទ្រង់។ កាលព្រះយេស៊ូវយាងឡើងពីទូកព្រះអង្គទតឃើញបុរសម្នាក់ចូលមករកព្រះអង្គ ដែលមានអារក្សនៅក្នុងខ្លួនខ្មាំងសត្រូវរបស់ព្រះគឺជាអារក្ស ដែលមានអ្នកដើរតាមវាជាច្រើន។ អ្នកដើរតាមទាំងនេះត្រូវបានគេហៅថា អារក្ស ឬវិញ្ញាណអាក្រក់។ ពេលខ្លះវិញ្ញាណអាក្រក់ទាំងនេះ រវល់នឹងបង្កបញ្ហាដល់មនុស្ស។ ពេលខ្លះអារក្សមួយអាចធ្វើការដោយខ្លួនឯងបាន។ ពេលខ្លះមានអារក្សជាច្រើន ដែលបានធ្វើការរួមគ្នា។ ពួកវាចូលចិត្តបង្កើតការភ័យខ្លាច និងការធ្វើទារុណកម្ម។ បុរសដែលបានជួបព្រះយេស៊ូវគឺរស់នៅក្នុងរូងភ្នំ។ គាត់មានវិញ្ញាណអាក្រក់ជាច្រើនបានធ្វើទុក្ខដល់គាត់។ ពួកវាបានធ្វើឱ្យគាត់យំដូចជាសត្វ ។

ពួកវាបានធ្វើឱ្យខ្លួនប្រាណគាត់មានរបួស។ ប្រសិនបើមាននរណាម្នាក់មកជួយបុរសនោះ អារក្សនឹងណ្តាលឱ្យគាត់វាយតបតវិញ ដូច្នេះគ្មាននរណាម្នាក់អាចចូលជិតគាត់បានទេ។ ប៉ុន្តែវិញ្ញាណអាក្រក់ដឹងថា ព្រះយេស៊ូវជាអ្នកណា។ វាបាននាំបុរសនោះឲ្យរត់មករកព្រះយេស៊ូវ ហើយស្រែកទៅកាន់ព្រះអង្គថា៖ «ហេតុអ្វីបានជាទ្រង់ រំខានដល់ទូលបង្គំនៅទីនេះ ឱព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុតអើយ! ទុកឱ្យទូលបង្គំនៅតែម្នាក់ឯងចុះ! សូមកុំធ្វើបាបទូលបង្គំឡើយ!" ព្រះយេស៊ូវមានព្រះបន្ទូលទៅអារក្សម្នាក់ក្នុងចំណោមពួកវាថា៖ «នែ, ម្នាលអារក្ស! ចូរថយចេញពីបុរសនេះទៅ!»។ ប៉ុន្តែដោយសារមានអារក្សជាច្រើនទៀត ដែលបង្ករបញ្ហាដល់បុរសនេះ ហើយវាក៏ស្រែកអង្វរឡើងរួមគ្នាថា៖ «កុំបណ្តេញយើងទៅឆ្ងាយអី! យើងចូលចិត្តនៅទីនេះ។ នៅពេលដែលពួកអារក្សកំពុងនិយាយ ព្រះយេស៊ូវបានឃើញជ្រូកមួយហ្វូងធំនៅលើភ្នំក្បែរនោះ។ ពួកអារក្សអង្វរថា៖ «សូមបញ្ជូនយើងរាល់គ្នាទៅជ្រកនៅក្នុងហ្វូងជ្រូកវិញចុះ។ នៅពេលនោះមានសត្វជ្រូកពីរពាន់ក្បាលនៅលើភ្នំ។ មានជ្រូកច្រើនណាស់! ព្រះយេស៊ូវបានអនុញ្ញាតឲ្យពួកវិញ្ញាណអាក្រក់ចេញពីបុរសនោះ ហើយចូលទៅក្នុងហ្វូងជ្រូក។

នៅពេលសត្វជ្រូកដឹងថា មានអារក្សនៅជុំវិញនោះពួកវាចាប់ផ្តើមរត់ដោយភ័យខ្លាច។ ហ្វូងជ្រូកបានរត់ចុះពីលើភ្នំចូលទៅក្នុងសមុទ្រ ហើយត្រូវបានលង់ទឹកស្លាប់អស់ទៅ។ សូម្បីតែវិញ្ញាណអាក្រក់ក៏ស្តាប់បង្គាប់ព្រះយេស៊ូវដែរ។ព្រះយេស៊ូវទ្រង់មានអំណាចខ្ពស់បំផុត។ ព្រះយេស៊ូវមានអំណាចខ្លាំងជាងពួកវិញ្ញាណកំណាចទៅទៀត។ បុរសដែលថែរក្សាហ្វូងជ្រូក មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពួកគេបានរត់ចូលទៅក្នុងទីក្រុង ហើយចាប់ផ្តើមប្រាប់មនុស្សគ្រប់គ្នានូវអ្វីដែលពួកគេបានឃើញ។ មនុស្សគ្រប់គ្នាត្រូវត្រលប់មកលើភ្នំវិញ ដើម្បីមើលដោយខ្លួនឯង។ អ្វីដែលគេបានឃើញ គឺបុរសដែលត្រូវបានអារក្សធ្វើទុក្ខទោស តែឥឡូវ គាត់អង្គុយនៅទីនោះយ៉ាងស្ងៀមស្ងាត់។ គាត់មានសុខភាពល្អនិងរឹងមាំ។ គាត់កំពុងគិតយ៉ាងច្បាស់។ គាត់បានជាសះស្បើយហើយ។ ប្រជាជនភ័យខ្លាចពួកគេខ្លាចអំណាចរបស់ព្រះយេស៊ូវ ។

ពួកគេបានប្រាប់ទ្រង់ឱ្យចាកចេញពីតំបន់របស់ពួកគេ ហើយទៅកន្លែងផ្សេងទៀត។ នៅពេលដែលព្រះយេស៊ូវ កំពុងយាងចូលក្នុងទូករបស់ទ្រង់វិញ បុរសដែលបានជានោះ បានសុំទៅជាមួយទ្រង់ដែរ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា «អត់ទេ»។ អ្នកត្រូវត្រលប់ទៅផ្ទះជួបក្រុមគ្រួសាររបស់អ្នកវិញ ហើយប្រាប់ពួកគេថា តើព្រះអម្ចាស់បានធ្វើអ្វីខ្លះសម្រាប់អ្នក និងថា តើទ្រង់ស្រឡាញ់អ្នកខ្លាំងប៉ុនណា។ បុរសនោះបានត្រឡប់ទៅក្រុងដេប៉ូរបស់គាត់ ហើយធ្វើតាមអ្វីដែលព្រះយេស៊ូវបានមានបន្ទូល។ គាត់ចាប់ផ្តើមប្រាប់ថា តើព្រះយេស៊ូវបានធ្វើអ្វីខ្លះដល់គាត់ ។ មនុស្សគ្រប់គ្នាដែលគាត់ប្រាប់បានភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ **(ម៉ាកុស ៥)**

# 4.03 ព្រះយេស៊ូវបណ្តេញអារក្ស - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សំគាល់

១) ព្រះយេស៊ូវបានឃើញបុរសម្នាក់ ដែលត្រូវវិញ្ញាណអាក្រក់ធ្វើទុក្ខទោសដល់គាត់។

២) សត្រូវរបស់ព្រះអម្ចាស់ គឺអារក្សជាអ្នក ដែលត្រូវបានគេហៅថា វិញ្ញាណអាក្រក់ ឬអារក្ស ។

៣) វិញ្ញាណអាក្រក់ដែលកំពុងធ្វើទុក្ខទោសបុរសនោះ ដឹងថា ព្រះយេស៊ូវជាព្រះរាជបុត្រាដ៏ខ្ពស់បំផុតនៃព្រះ។ ពួកអារក្សបានទូលព្រះអង្គថា៖ «សូមទុកឲ្យទូលបង្គំនៅទីនេះចុះ! »។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលប្រាប់អារក្សមួយឲ្យចេញពីបុរសនោះរួចទៅហើយ។

៤) ទោះជាយ៉ាងណា មានវិញ្ញាណអាក្រក់ច្រើនទៀត ដែលបានធ្វើទុក្ខទោសដល់បុរសនេះ។ មានអារក្សជាច្រើន។ ពួកវាបានទូលអង្វរព្រះយេស៊ូវឲ្យពួកវាបាននៅទីនោះ។ ពួកវាមិនចង់ចាកចេញពីទីនោះទេ។ ពួកវាទូលអង្វរថា៖ «សូមបញ្ជូនទូលបង្គំរាល់គ្នាទៅជ្រកនៅក្នុងហ្វូងជ្រូកចុះ»។ ព្រោះមានហ្វូងជ្រូកដ៏ធំមួយនៅលើភ្នំក្បែរនោះ ។

៥) ព្រះយេស៊ូវបានអនុញ្ញាតឲ្យពួកវា ចូលក្នុងហ្វូងជ្រូកនោះ ។ ពេលនោះសត្វជ្រូកមានការភ័យខ្លាចយ៉ាងខ្លាំងរហូតដល់រត់ចុះពីលើភ្នំចូលទៅក្នុងបឹង ហើយលង់ទឹកស្លាប់អស់ទៅ ។

៦) បុរសដែលមើលថែជ្រូកបានរត់ចូលទៅក្នុងក្រុង ហើយប្រាប់មនុស្សគ្រប់គ្នានូវអ្វីដែលបានកើតឡើង។ ប្រជាជនបានសុំឲ្យព្រះយេស៊ូវចាកចេញពីទីនោះទៅ ។

៧) ព្រះយេស៊ូវបានមានបន្ទូលទៅកាន់បុរស ដែលបានជាសះស្បើយឱ្យត្រឡប់ទៅក្រុងរបស់គាត់វិញ ហើយប្រាប់ពីអ្វីដែលព្រះអម្ចាស់ ទ្រង់បានធ្វើសម្រាប់គាត់ ដូច្នេះ នោះគឺជាអ្វីដែលគាត់បានធ្វើ ។

**សំណួរ:**

១) តើអារក្ស ឬវិញ្ញាណអាក្រក់ជាអ្វី?

២) តើអារក្សបានទូលសុំព្រះយេស៊ូវឲ្យបញ្ជូនពួកគេទៅណា?

៣) តើមានអ្វីកើតឡើងចំពោះហ្វូងជ្រូក?

៤) តើប្រជាជនក្នុងទីក្រុង មានប្រតិកម្មយ៉ាងណាចំពោះអ្វី ដែលពួកគេបានឃើញ?

៥) តើបុរសដែលបានជាសះស្បើយបានធ្វើអ្វីខ្លះ?

**ចម្លើយ:**

១) អារក្ស ឬវិញ្ញាណអាក្រក់ គឺជាសត្រូវរបស់ព្រះអម្ចាស់ ដែលជាអ្នកដើរតាមអារក្ស ។

២) អារក្សបានទូលសុំព្រះយេស៊ូវ ឲ្យបញ្ជូនវាទៅជ្រកនៅកណ្តាលហ្វូងជ្រូក ។

៣) ហ្វូងជ្រូកភ័យខ្លាច រហូតដល់ពួកវារត់ចុះពីលើភ្នំ ចូលទៅក្នុងបឹងហើយលង់ស្លាប់អស់ទៅ ។

៤) ប្រជាជនពីក្នុងទីក្រុងបានសុំព្រះយេស៊ូវ ឲ្យទ្រង់ចាកចេញពីតំបន់របស់ពួកគេ ។

៥) បុរសដែលបានជាសះស្បើយ បានត្រឡប់ទៅក្រុងរបស់គាត់វិញ ហើយប្រាប់មនុស្សគ្រប់គ្នា នូវអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់គាត់ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org